# របៀបអានភាសាបាលី

ក្នុងភាសាបាលី មានស្រៈ៨តួ: ចែកជា២ប្រភេទគឺ:

ក-ស្រៈនិស្ស័យ (Voyelles simples)

I ា ិ ី ុ ូ េ ោ ំ(៤)

a ā i ī u ū e o ṃ

ខ-ស្រៈពេញតួ (Voyelles entières)

អ អា ឥ ឦ ឧ ឩ ឯ ឱ

a ā i ī u ū e o

ស្រៈ៨តួនេះ ចែកជា២ពួក គឺ:

I ិ ុ មានសម្លេងខ្លី ហៅថា រស្សៈ ឧទាហរណ៍: អគតិ

ា ី ូ េ ោ មានសម្លេងវែង ហៅថា ទីឃៈ ឧទាហរណ៍: អាហារោ។

ស្រៈពេញតួ គេយកទៅប្រើជាតួអក្សរបង្កើតពាក្យបានដូចព្យញ្ជនៈដែរ។

---

(៤)-និគ្គហិតសំរាប់ដាក់លើស្រៈ ៣តួ គឺ I(អ) ិ(អិ) ុ(អុ)

កើតបានជាសម្លេង អាំង អឹង អុង ឧទាហរណ៍ :

កំ អានថា កាំង តំ អានថា តាំង

កឹ អានថា កឹង តឹ អានថា តឹង

កុំ អានថា កុង តុំ អានថា តុង។

## គ-ព្យញ្ជនៈ (Consonnes) ក្នុងភាសាបាលីមាន៣៣តួៈ

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ |
| k | kh | g | gh | ṅ | c | ch | j | jh | ñ | ṭ | ṭh | ḍ | ḍh | ṇ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម |
| t | th | d | dh | n | p | ph | b | bh | m |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | អ | ។ |
| y | r | l | v | s | h | ḷ | a | |

គេចែកចេញជាវគ្គ ដូចនេះ ◌ៈ

ក ខ គ ឃ ង = កវគ្គ

ច ឆ ជ ឈ ញ = ចវគ្គ

ដ ឋ ឌ ឍ ណ = ដវគ្គ

ត ថ ទ ធ ន = តវគ្គ

ប ផ ព ភ ម = បវគ្គ

យ រ ល វ ស ហ ឡ អ = សេសវគ្គ ។

អក្សរបាលី គេមិនអាន ក ខ គ ឃ ង ដូចភាសាខ្មែរយើងទេ

ក អានថា កៈ ខ អានថា ខៈ គ អានថា គៈ ឃ អានថា ឃៈ ង អានថា ងៈ ……… រៀងរហូតដល់ចប់។ ប៉ុន្តែ អក្សរ ប មិនអានថា បៈ ទេ គេអានថា ប៉ៈ។

<u>**១- បើអក្សរកាយត្ត**</u> ត្រូវអានគ្រប់តួអក្សរ ព្រោះមិនមានតួណាប្រកបឲ្យតួណាទេ

<u>ឧទាហរណ៍:</u> សយនៈ ត្រូវអានថា សៈយៈនៈ អានថា សយនៈ មិនបានទេ

ពហុល ត្រូវអានថា ពៈហុលៈ អានថា ពៈហុល មិនបានទេ។

<u>**២- អក្សរតម្រួតគ្នា ហើយអក្សរតម្រួតនោះនៅក្នុងវគ្គជាមួយគ្នា**</u>

អក្សរខាងលើគ្រាន់តែជាតួប្រកបអក្សរខាងដើម មិនអាចបញ្ចេញសម្លេងខ្លួនឯងបានទេ។ ចំណែកជើងអក្សរខាងក្រោម មានសិទ្ធិចេញសម្លេង និងប្រើប្រាស់ស្រៈខាងលើនោះផង <u>ឧទាហរណ៍:</u> សក្ក ត្រូវអានថា សាក់ កៈ គឺអានសង្កត់ សាក់ ឲ្យធ្ងន់ នឹងអានថា សៈ កៈ មិនបានទេ ឬ នឹងអានថា សៈ កៈកៈ មិនបានទេ ព្រោះអក្សរលើគ្រាន់តែតួប្រកបប៉ុណ្ណោះ។ សច្ចិ ត្រូវអានថា សាច់ ចិ នឹងអានថា សៈ ចិ ឬ សាច់ ចៈចិ មិនបានទេ។

<u>**៣- អក្សរវគ្គជទែតម្រួតលើអក្សរសេសវគ្គក្តី អក្សរសេសវគ្គតម្រួតលើអក្សរវគ្គជទែក្តី**</u>

អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង ជាតួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង <u>ឧទាហរណ៍:</u> សក្យ ត្រូវអានថា សាក់ ក្យៈ នឹងអានថា សៈ ក្យៈ ឬ សាក់ យៈ មិនបានទេ។ តត្រ ត្រូវអានថា តាត់ ត្រៈ នឹងអានថា តៈ ត្រៈ ឬ តាត់ រៈ មិនបានទេ។ កត្វា ត្រូវអានថា កាត់ ត្វា នឹងអានថា កៈ ត្វា ឬ កាត់ វ៉ា មិនបានទេ។ តណ្ហា ត្រូវអានថា តាន់ ណ្ហា នឹងអានថា តៈ ណ្ហា ឬ តាន់ ហា

មិនបានទេ។ តស្មា ត្រូវអានថា តាស់ ស្មា នឹងអានថា ត: ស្មា ឬ តាស់ ម៉ា មិនបានទេ។ កល្បត្រូវអានថា កាល់ ល្ប: នឹងអានថា ក: ល្ប: ឬ កាល់ ប៉: មិនបានទេ។

<u>**៤- បើអក្សរសេសវគ្គ តម្រួតគ្នាឯង**</u>

-<u>តួនិងជើង ដូចគ្នា</u> ដូចពាក្យថា អយ្យា តួលើគ្រាន់តែជាតួប្រកប មិនអាចបញ្ចេញសម្លេងបានទេ អយ្យា ត្រូវអានថា អ័យ យ៉ា នឹងអានថា អ: យ៉ា ឬ អ: យ:យ៉ា មិនបានទេ។

-<u>អក្សរតម្រួតតួផ្សេងគ្នា</u>(*) ដូចពាក្យ មយ្ហំ ត្រូវអានថា ម័យ យ្ហំ នឹងអានថា ម: យ្ហំ ឬ ម័យ ហំ មិនបានទេ។ អស្វ ត្រូវអានថា អ័ស ស្វ: នឹងអានថា អ: ស្វ: ឬ អ័ស វ: មិនបានទេ។

---

(*)អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង ជាតួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។